# ទស្សនៈវិស័យ បេសកកម្ម និងគុណតំលៃអង្គការ

ដោយ ឡេងឆាយ

## ទស្សនៈវិស័យ Vision

ទស្សនៈវិស័យជារូបភាពគោលមួយនៃជោគជ័យ ដែលនឹងកើតឡើង ក្នុងន័យរួមចំណែកដល់សង្គម។ វាឆ្លើយនឹងសំនួរថាតើ "ជោគជ័យនឹងមានរាងដូចម្តេច" ។ វាជាការស្វែងរកនូវរូបភាពនៃជោគជ័យមួយ ដែលជំរុញទឹកចិត្តអោយបុគ្គលិកខំធ្វើការជាមួយគ្នា។ ទស្សនៈវិស័យមួយស្ថិតនៅក្រៅការត្រួតត្រារបស់អង្គការមួយ មានន័យថាអង្គការច្រើនរួមចំណែកទៅសំរេចទស្សនៈវិស័យមួយ។

*ឧទាហរណ៍:*

- សង្គមមួយដែលបុរស និងស្ត្រីមានសិទ្ធិ និងឪកាសស្មើរគ្នា។
- ប្រជាពលរដ្ឋជនបទកម្ពុជារស់នៅក្នុងសន្តិភាព និងភាពរុងរឿង។
- សង្គមមួយដែលប្រជាពលរដ្ឋរស់នៅសុខសាន្ត ដោយស្មើរភាពគ្នាចំពោះមុខច្បាប់។

## បេសកកម្ម Mission

បេសកកម្មឆ្លើយនឹងសំនួរថា តើហេតុអ្វីបានជាមានអង្គការ(គោលបំណង), អង្គការនោះធ្វើការងារផ្នែកអ្វី (សកម្មភាពចំបងៗ/វិធីសាស្ត្រ) ហើយអង្គការនោះបំរើអ្នកណា (ក្រុមគោលដៅ)។ ឃ្លាបេសកកម្មមួយមានពីរផ្នែក៖

- ឃ្លាគោលបំណង: បញ្ជាក់ពីអ្វីដែលអង្គការអ្នកចង់សំរេច។ ឧ.លើកកំពស់សិទ្ធិស្ត្រី លើកកំពស់កំរិតជីវភាព លើកកំពស់យុត្តិធម៌។ល។
- ឃ្លាសកម្មភាព ឬអាជីវកម្ម: សកម្មភាព ឬកម្មវិធីដែលអង្គការអ្នកជ្រើសរើសដើម្បីសំរេចគោលបំណង។ ឧ.ផ្តល់សេវាអប់រំ និងប្រឹក្សាយោបល់ ផ្តល់សេវាហិរញ្ញវត្ថុ ធ្វើការតស៊ូមតិដើម្បីសិទ្ធិ។ល។

This learning article shared by Cambodian Learning Facilitators (www.camlefa.org). All rights reserved.

ឧទាហរណ៍៖

- ផ្តល់សេវាអប់រំ និងប្រឹក្សាយោបល់ ដល់ស្ត្រីរងគ្រោះនៅប្រទេសកម្ពុជា ដើម្បីលើកកំពស់ សិទ្ធិនិងឪកាសស្ត្រី។
- លើកកំពស់កំរិតជីវភាពរស់នៅ របស់ប្រជាពលរដ្ឋជនបទ តាមរយៈការផ្តល់សេវាហិរញ្ញវត្ថុ ដែលឆ្លើយតបនឹងតំរូវការអាជីវកម្មខ្នាតតូចរបស់គេ។
- ធ្វើការតស៊ូមតិ ដើម្បីសិទ្ធិអ្នកក្រ និងអ្នកងាយរងគ្រោះ ដើម្បីលើកកំពស់យុត្តិធម៌ក្នុងសង្គម។

## គុណតំលៃ Values

គុណតំលៃជាជំនឿដែលណែនាំ ឬជំរុញដល់អាកប្បកិរិយាឬសកម្មភាព។ គុណតំលៃអង្គការជាជំនឿដែលបុគ្គលិកមានរួមគ្នា ហើយព្យាយាមដាក់បញ្ចូលទៅក្នុងការអនុវត្តជាក់ស្តែង។ គុណតំលៃមានសារៈសំខាន់ណាស់ចំពោះអង្គការ ព្រោះវាជួយណែនាំអាកប្បកិរិយាបុគ្គលិកក្នុងការបំពេញការងាររបស់គេ ជួយបង្កើនប្រសិទ្ធភាពអង្គការ និងសំរេចបេសកកម្ម និងទស្សនៈវិស័យ។

*ឧ.ពាក្យគុណតំលៃ:* ការងារក្រុម ការគោរពចំរុះភាព ភាពស្មោះត្រង់ ភាពជាអាជីពសុច្ចរិតភាព លទ្ធផលជាចំបង សមភាពយេនឌ័រ ការអភិវឌ្ឍបុគ្គលភាព ភាពច្នៃប្រឌិត ការរៀនសូត្រ។ល។

*ឧ.ឃ្លាគុណតំលៃ:*

- យើងជឿថាបរិភោគបន្លែមានសុខភាពល្អជាងបរិភោគសាច់ជ្រូក។
- យើងជឿថាការរៀនសូត្រជាបនបន្ទាប់នឹងលើកកំពស់ប្រសិទ្ធភាពអង្គការ។
- យើងជឿថាស្ត្រីអាចរួមចំណែកយ៉ាងលេចធ្លោរក្នុងការផ្លាស់ប្តូរសង្គម។

*សំគាល់:* យើងត្រូវមានដំណើរការមួយដែលមានការចូលរួមយ៉ាងពេញលេញ និងការសំរបសំរួលសមស្រប ដើម្បីបង្កើតទស្សនៈវិស័យ បេសកកម្ម និងគុណតំលៃរួម ដែលល្អ។

This learning article shared by Cambodian Learning Facilitators (www.camlefa.org). All rights reserved.